00294014

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 03 / 2009
ម៉ោង (Time/Heure): 14 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ

**Case File/Dossier No. 001/18-07-2007/ECCC/TC**

| | |
|---|---|
| នៅចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៩ |
| ចំណាត់ថ្នាក់នៃឯកសារ: | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01 / APR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

# សេចក្តីសម្រេចអំពីសំណើសុំឲ្យសមាជិករបស់ក្រុមការពារក្តីចូលជួបជនជាប់ចោទ

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្កេក អ៊ាវ ហៅ "ឌុច"

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីការពារក្តី**
ការ សាវុត្ថ
François ROUX

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អវតក”)

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោម “តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច” ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨

**ក្រោយពីបានទទួល** សំណើរបស់សហមេធាវីជនជាប់ចោទ នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៩ ដែលក្នុងសំណើនោះសហមេធាវីស្នើសុំអនុញ្ញាតឲ្យកញ្ញា Virginie CHARPENTIER ដែលជាកម្មសិក្សាការិនីផ្នែកច្បាប់នៅក្នុងក្រុមការពារក្តី អាចចូលជួបជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៩[1]

**ក្រោយពីបានទទួល** សំណើបន្ទាន់របស់សហមេធាវីជនជាប់ចោទ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ ដែលក្នុងសំណើនោះ សហមេធាវីស្នើសុំអនុញ្ញាតឲ្យកញ្ញា Lucile NATTIEZ ដែលជាអ្នកពិគ្រោះយោបល់ផ្នែកច្បាប់នៅក្នុងក្រុមការពារក្តី អាចចូលជួបជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រហូតដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩[2]

**ក្រោយពីបានទទួល** សំណើបន្ទាន់របស់សហមេធាវីជនជាប់ចោទ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ដែលក្នុងសំណើនោះ សហមេធាវីស្នើសុំអនុញ្ញាតឲ្យលោកស្រី Marie-Paule CANIZARES ដែលជាអ្នកពិគ្រោះយោបល់ផ្នែកច្បាប់នៅក្នុងក្រុមការពារក្តីអាចចូលជួបជនជាប់ចោទនៅក្នុងមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[3]

[1] ឯកសារ E10។

[2] ឯកសារ E29។

[3] ឯកសារ E35។

E37

**ដោយយល់ឃើញថា** ការអនុញ្ញាតឱ្យសមាជិករបស់ក្រុមការពារក្តីចូលជួបជនជាប់ចោទដោយមានការឃ្លាំមើលគឺ មានផលប្រយោជន៍ក្នុងការត្រៀមលក្ខណៈការពារក្តីប្រកបដោយប្រសិទ្ធភាព

## ហេតុដូច្នេះសម្រេច

**អនុញ្ញាត** តាមសំណើទាំងនេះដោយឈរលើលក្ខខណ្ឌដែលថារាល់ការចូលជួបជនជាប់ចោទរបស់កញ្ញា CHARPENTIER កញ្ញា NATTIEZ និងលោកស្រី Marie-Paule CANIZARES ត្រូវតែមានការអមដំណើរដោយសមាជិកណាម្នាក់របស់ក្រុមការពារក្តី ដែលរួមមានសហមេធាវី អ្នកពិគ្រោះយោបល់ច្បាប់ និងអ្នកគ្រប់គ្រងសំណុំរឿង។ ។ល

ភ្នំពេញ ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៨

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE * E C C C * C E T C

និល - ណុន